# លក្ខណៈជីវសាស្ត្រ និងការចម្រាញ់ប្រេងដើមម្រះព្រៅភ្នំ

*Dysoxylum Loureiri Pierri*

ដោយរដ្ឋបាលព្រៃឈើ

## លក្ខណៈជីវសាស្ត្រ

### ១. សេចក្ដីផ្ដើម

ដើមម្រះព្រៅភ្នំ ជាប្រភេទឈើដែលរងនូវការគំរាមកំហែងនាពេលបច្ចុប្បន្ននេះ ដោយសារតែការចំរាញ់ប្រេងរបស់វា។ មនុស្សភាគតិចណាស់ដែលស្គាល់ថា ដើមម្រះព្រៅភ្នំ ជាប្រភេទដើមឈើធំដែលដុះនៅក្នុងព្រៃជ្រៅលាយឡំនឹងប្រភេទឈើមានតម្លៃផ្សេងៗទៀត ។ ប៉ុន្ដែក៏មានមតិយល់ច្រឡំផងដែរថា ដើមម្រះព្រៅភ្នំ និង ដើមទេព្វិរូជាប្រភេទឈើតែមួយ ។ ជាការពិតណាស់ប្រភេទឈើទាំងពីរនេះមានលក្ខណៈខុសគ្នា និង ជាប្រភេទឈើពីរប្រភេទផ្សេងគ្នា ទាំងទម្រង់ដើម ស្លឹក សំបក អំបូរ និង គ្រួសារជាដើម ។

### ២.លក្ខណៈរបស់ដើមម្រះព្រៅភ្នំ

#### ក-ឈ្មោះវិទ្យាសាស្ត្រ

- ឈ្មោះភាសាខ្មែរ : ម្រះព្រៅភ្នំ
- ឈ្មោះវិទ្យាសាស្ត្រ : *Dysoxylum loureiri* Pierri
- អំបូរ : Meliaceae

#### ខ-លក្ខណៈជីវសាស្ត្រ



ដើមម្រះព្រៅភ្នំដុះក្នុងព្រៃធម្មជាតិ

ដើមម្រះព្រៅភ្នំមានដើមកំណើតពីធម្មជាតិហើយប្រភេទនេះច្រើនតែដុះនៅតំបន់ដែលជាតំបន់ខ្ពង់រាបខ្ពស់ៗ ដែលមានរយៈកម្ពស់ចាប់ពី ១៦៧ ម ឡើងទៅធៀបនឹងនីវ៉ូទឹកសមុទ្រ។ ប្រភេទនេះបើភ្នំកាន់តែខ្ពស់នោះ កាន់តែសំបូរប្រភេទដើមម្រះព្រៅភ្នំនេះដុះ ហើយនៅក្នុងប្រទេសកម្ពុជាគេសង្កេតឃើញថា ដើមម្រះព្រៅភ្នំដុះនៅភាគខាងជើងឈាងខាងលិចនៃប្រទេសដូចជាខេត្តបាត់ដំបង(ចាប់ពីព្រំដែនស្រុកសំឡូត) ខេត្តពោធិសាត់ (ស្រុកវាលវែង) រហូតដល់ខេត្តកោះកុង ដែលភ្ជាប់តាំងពីខេត្តពោធិសាត់ និង អាចឃើញមានដុះនៅខេត្តកំពង់ធំដែរ (Dy Phon, 2000 ) ។

តំបន់ទាំងនោះសុទ្ធតែជាព្រៃស្រោងស្រស់ៗ ហើយមានកម្រិតកម្ពស់ទឹកភ្លៀងខ្ពស់ជាតំបន់ត្រជាក់សំបូរទៅដោយជ្រោះជ្រលងដងអូរនៅពាសពេញខ្នងភ្នំ ។ ចំពោះប្រភេទនេះ វាចូលចិត្តដុះនៅក្នុងជីវសាស្ត្រព្រៃស្មុគ្រស្មាញ ដែលមានរុក្ខជាតិច្រើនប្រភេទរួមគ្នាទាំងវល្លិចាក់ស្រេះគ្នាស្មុគស្មាញជាច្រើនប្រភេទ។ រហូតមកដល់សព្វថ្ងៃនេះ រុក្ខជាតិម្រះព្រៅភ្នំពុំទាន់មានការកែប្រែពីព្រៃធម្មជាតិឱ្យក្លាយទៅជាព្រៃដាំ ឬ រុក្ខជាតិដែលទទួលការការពារថែរក្សាដោយក្រុមហ៊ុនរដ្ឋ ឬ ឯកជនណាមួយនៅឡើយទេ (សួន ធីរស់, ២០០៥) ។

#### គ-លក្ខណៈរចាយ

ដើមម្រះព្រៅភ្នំ ចាប់បង្ហាញពីភាពងាប់របស់វាដោយចាប់ផ្ដើមងាប់មែកម្ដងមួយៗ រួចងាប់ទាំងដើមតែម្ដង ។ ភាគច្រើន នៃដើមងាប់ក្នុងធម្មជាតិរលំដួលដោយសារខ្យល់ ភ្លៀង រួចហើយពុកផុយតាមដំណើរធម្មជាតិ ។ ដោយសារ ដើមម្រះព្រៅភ្នំ ដុះតែនៅក្នុងធម្មជាតិក្នុងតំបន់ព្រៃឈើសើមជានិច្ច គេមិនឃើញមានភ្លើងព្រៃឆេះដូចនៅក្នុងតំបន់ព្រៃល្បោះនោះទេ (លិ វុឌ្ឍី, ២០០៥) ។

ដើមម្រះព្រៅភ្នំដុះនៅលើដីល្បាយខ្សាច់ ក្បែរមាត់អូរពិសេសតាមតំបន់ព្រៃស្រោងសើមជានិច្ច។ ដើមម្រះព្រៅភ្នំមានដុះជាពិសេសនៅតំបន់ព្រៃឈើសើម មាត់សមុទ្រនៃប្រទេសកម្ពុជា និង វៀតណាមភាគខាងត្បូង ។ ទោះបីនៅក្នុងតំបន់ជួរភ្នំក្រវាញដូចគ្នាក៏ដោយគេមិនឃើញមានដើមម្រះព្រៅភ្នំ ដុះនៅ

តាមចំណែកតូចៗនៃតំបន់ព្រៃល្បោះដែរ ។ ក្នុងតំបន់ជួរភ្នំក្រវាញ គេបានដឹងថាដើមម្រះព្រៅភ្នំមានដុះនៅតាមតំបន់មួយចំនួនដែលតាមតំបន់ដែលអ្នកស្រុកហៅ ដូចជា អូរសោម ដែលមានផ្ទៃប្រមាណជា១០គីឡូម៉ែត្រការ៉េ រួចលាតសន្ធឹងដល់ភូមិឈើទាលជ្រុំ ភ្នំសំកុស (ភ្នំខ្មោច) ខ្នងទឹករេ ជួរខ្នងភ្នំម្ទេស ជួរភ្នំប៉ែតសិប តំបន់ភ្នំមួយពាន់ប្រាំរយ (អ្នកស្រុកនិយមហៅថា ភ្នំមួយពាន់ប្រាំ)សំឡូត ភ្នំស្វាអិល និង តំបន់ថ្មដា ជាប់ព្រំដែនថៃឡង់ (ស រ៉ោ និង គង់ ណាត ជួបផ្ទាល់មាត់ ) ។ គេឃើញដើម ម្រះព្រៅភ្នំ មានដុះនៅក្នុងតំបន់ថ្មបាំង ខេត្តកោះកុងផងដែរ ។ នៅក្នុងតំបន់ព្រំប្រទល់ខេត្តបីគឺ ខេត្តកំពង់ស្ពឺ កោះកុង និង ពោធិសាត់ ដើមម្រះព្រៅភ្នំដុះនៅតាមទីតាំងដូចជា នៅខាងលិចភូមិតាសាយ ក្អមតូច ក្អមធំ



*ដើមម្រះព្រៅភ្នំដែលងាប់ដោយភ្លើងឆេះ នៅតំបន់ អូរសោម ខេត្តពោធិសាត់*

និង នៅរាំងខយ (ឈឹម ណើម សំភាសន៍ផ្ទាល់មាត់) ។

លោក គង់ ណាត បញ្ជាក់ថា នៅតំបន់ដែលគាត់បានឃើញកន្លងមកនេះ មិនសូវឃើញមានដុះដើមម្រះព្រៅភ្នំជាជ្រុំនោះទេ តែវាដុះភាគច្រើនមួយ ឬពីរដើមនៅតាមកន្លែងផ្សេងៗពីគ្នា ។ នេះបញ្ជាក់ឱ្យឃើញថា ដើមម្រះព្រៅភ្នំ មិននៅសល់ជាជ្រុំទេ ព្រោះដើមដែលចាស់មានអង្កត់ផ្ចិតលើសពី ៦០ ស.ម ត្រូវងាប់ដោយធម្មជាតិ ។ រីឯនៅតំបន់ព្រំប្រទល់ខេត្តទាំងបី គេអាចឃើញដើមម្រះព្រៅភ្នំដុះជាជ្រុំៗ ផងដែរតែមិនសូវមានច្រើនកន្លែងទេ ។ ប៉ុន្តែជ្រុំនីមួយៗសម្បូរទៅដោយដើមដែលមានអង្កត់ផ្ចិតតូចៗ (អង្កត់ផ្ចិតតូចជាង ៦០ ស.ម) ។ ៨០ ភាគរយ នៃដើមម្រះព្រៅភ្នំ ដែលមានអង្កត់ផ្ចិតលើសពី ៦០ ស.ម គឺងាប់ដោយធម្មជាតិ ។ នៅពេលដែលវាមានមុខកាត់ធំ ដូចខាងលើនេះ វាចាប់ផ្តើមរលួយឬស ប្រហោងក្នុងដើម រួចរលំដួលតែម្តង (លិ វុឌ្ឍី, ២០០៥) ។

## ៣. លក្ខណៈរុក្ខសាស្ត្ររបស់ដើមម្រះព្រៅភ្នំ

### ក-ដើម

ដើមម្រះព្រៅភ្នំជាប្រភេទដើមឈើធំមានកម្ពស់ចាប់ពី ១១ ទៅ ២០ ម និង អាចមានអង្កត់ផ្ចិតរហូត ២៥០ ស.ម ។ រុក្ខជាតិនេះពុំមានសាច់ដើមហាប់ណែនល្អទេ ព្រោះរុក្ខជាតិ ម្រះព្រៅភ្នំនេះមានដើមកាន់តែធំកាន់តែប្រហោង ។ នៅក្នុងតួដើមរបស់វាមានជាតិប្រេងធ្វើឱ្យសាច់ឈើប្រេះបណ្តូលដោយខ្លួនឯង ។ផ្នែកដើមដែលមានសាច់ហាប់ណែនល្អប្រមាណ ពី ១,៥ ម ទៅ ២,៤ ម ពីឬសប៉ុណ្ណោះ ។

ចំពោះសាច់ដើម នៅខាងលើព័ទ្ធជុំវិញប្រហោងមានកំរាស់ប្រមាណពី ៥ ស.ម ទៅ ១៥ ស.ម ។ ដើមវាបើកាលណាដុះ នៅជិតអូរនោះវាពុំសម្បូរពកដើមនោះទេ ផ្ទុយទៅវិញបើដុះនៅតាមចំរាក់ភ្នំដែលឆ្ងាយពីទឹកនោះ វាសំបូរទៅដោយពកណាស់ តែបើដើមដុះនៅទីរាបនៃខ្នងភ្នំខ្ពស់ៗ នោះច្រើនតែមានដើមតូច ហើយ



*ដើមម្រះព្រៅភ្នំដែលកាប់ដួលនៅតំណាក់ក្រូច(អូរសោម)*

ពុំសូវមានពកទេ ព្រោះខ្វះជាតិទឹក (សួន ធីរស់, ២០០៥) ។

### ខ-មែក

ដើមម្រះព្រៅភ្នំពុំសូវសម្បូរមែកវែងៗនោះទេ វាមានមែកសាខាខ្លីៗប៉ុណ្ណោះ ដោយសារដើមរបស់វាមានប្រហោងនៅខាងក្នុងធំៗនាំឱ្យសាច់ឈើស្តើង មែករបស់វាច្រើនតែដុះនៅចំហៀង ដែលនៅសល់សាច់ឈើក្រាស់ជាងចំហៀងដែលនៅសល់សាច់ឈើស្តើង ។

មែកដើមម្រះព្រៅភ្នំសម្បូរទៅដោយជំពាមណាស់នៅតាមចុងមែកមានរាងជាជ្រុងៗ ហើយមានពណ៌ខ្មៅមានរាងជាគំពកស្លឹកនៅតាមថ្នាំងមែក និង គល់ស្លឹករបស់វា ។

### គ-ស្លឹក

ប្រភេទរុក្ខជាតិស្លឹកទោល តំរៀបឆ្លាស់ទល់មុខគ្នានៅគល់ស្លឹកមានពកស្លឹក មានទងរាងវែង ហើយមានប្រវែងពី ១០ ទៅ ១១ ស.ម និង មានទំហំ ៤ ទៅ ៥ ស.ម ចុងស្លឹកជាប្រភេទស្លឹកពេញស្រួច ស្លឹករបស់វាមានពណ៌បៃតងចាស់នៅផ្នែកខាងលើ

និង ផ្នែកខាងក្រោមបន្ទះស្លឹកមានពណ៌ប្រផេះ ដូចជាម្សៅៗ



*ស្លឹកដើមម្រះព្រៅភ្នំនៅភូមិឈើទាលជ្រុំ*

(សួន ធីរស់, ២០០៥)។

ស្លឹកមានជាតិប្រេងតិចៗ ដែលមើលទៅហាក់ដូចជាឃ្លីកៗ ស្អិលៗ និយាយរួមមានក្លិនឈ្ងុល ហិរៗពេលខាំវា នៅចុងមែកនេះ ។ ស្លឹកដើមម្រះព្រៅភ្នំមានទ្រនុងស្លឹកពី ១០ ទៅ ១៤ គូរ។ ពេលហាលស្ងួតគឺមានក្លិនឈ្ងុលខ្លាំង (សួន ធីរស់, ២០០៥)។

**ឃ-សំបក គល់ និង ឫស**

ដើមម្រះព្រៅភ្នំ មានសំបកពណ៌ក្រហមត្នោតស្រាល (ក្រហមស្រាលរាងស្រគាំ) ហើយជាប្រភេទរុក្ខជាតិដែលមានសំបកក្រាស់ល្មមប្រមាណជា ១,៥ ទៅ ២ ស.ម ជាប្រភេទរុក្ខជាតិដែលមានសំបកជាក្រម៉ុតូចៗ ខាំជាប់នៅដើម ប្រេះតិចៗ ចាក់ជាក្រឡាសំណាញ់នៅពេលដូរសំបកចាស់ ក្រម៉ុសំបកនេះជ្រុះចេញដែរ។

គល់ និង ឫសរបស់វាមានរាងព្រីង ដែលជាប់នៅនឹងដីតិចៗ រុក្ខជាតិនេះមានគល់ និង ឫសស្អាតល្អ អាចយកមកប្រើប្រាស់ឆ្លាក់ធ្វើជាគ្រឿងសង្ហារឹមបានច្រើនប្រភេទ ។ គល់មានកម្ពស់ ១,៥ ម ទៅ ២,៤ ម ពីដី ជាកន្លែងដែលសម្បូរទៅដោយជាតិប្រេងដែលជាចំនុចពិសេសដែលអាចអនុញ្ញាតឱ្យផលិតករ យកមកប្រើ



*សំបកដើមម្រះព្រៅភ្នំនៅឈើទាលជ្រុំខេត្តពោធិសាត់*

ប្រាស់ក្នុងការចំរាញ់យកប្រេងរបស់វាបាន (សួន ធីរស់, ២០០៥)

**ង-ផ្កា ផ្លែ និង គ្រាប់**

ដើមម្រះព្រៅភ្នំ ពុំសូវមានផ្កាញឹកញាប់ទេ ព្រោះក្នុងរយៈពេលពី១០ទៅ១៥ឆ្នាំ ទើបចេញផ្កាម្ដង ដែលនេះបង្ហាញពីលក្ខណៈពិសេសរបស់ដើមម្រះព្រៅភ្នំ ។ រដូវចេញផ្ការបស់វា គឺចន្លោះពីខែ កុម្ភៈ ទៅ ខែ មីនា ។ ផ្ការបស់វាមានប្រាំបីសន្ទះ រួមបញ្ចូលគ្នានៅក្នុងបំពង់ខ្លីមួយ ហើយវាមានរោមខ្លីៗ នៅខាងក្រោមរចនាបថទ្រង់ទ្រាយឆ័ត្រ ហើយមានអូវែរាងមូល ដែលត្រូវគ្របដោយស្រទាប់ក្រាស់នៃរោមគ្រាប់របស់វាមាន ៣ ទៅ ៤ បន្ទប់ ហើយផ្លែនីមួយៗមាន ២ គ្រាប់ ។ ផ្កាវាគឺពណ៌លឿងចាស់ នៅក្នុងរោមខ្លីៗយ៉ាងក្រាស់វែង ពី ៣ ទៅ ៤ ស.ម ព័ទ្ធជុំវិញរាងមូល ហើយរោមខ្លីៗជាស្រទាប់ខាងក្រៅនៃផ្កាក្រពុំនោះ គឺត្រូវបានបង្កើតដោយស្លឹកពិណខៀវ នៅក្រោមគ្របកផ្កា ៤ នៅ លើគ្របកផ្កា ៤ រៀបឡើងពីរជង តាមស្រទាប់ខាងក្រៅផ្កាក្រពុំ ហើយនឹងរោមខ្លីៗនៅលើផ្ទៃខាងក្រៅ (ផ្ការបស់វាលំនាំជាផ្កា វល្លិ៍ថ្មីង)។

ក្រោយពេលក្ដីបអស់រយៈពេលពេញរដូវប្រាំងផ្លែរបស់វាគឺចាប់ផ្ដើមទុំ។ ផ្លែវាជាប្រភេទផ្លែទោលដែលមានរាងមូលទ្រវែង ដែលមាន ៣ សន្ទះ ហើយក្នុងមួយសន្ទះមានមួយគ្រាប់។ ក្នុងកំឡុងពេលសិក្សាស្រាវជ្រាវ ពុំទាន់បានសង្កេតឃើញគ្រាប់របស់វាមានរាងយ៉ាងណានៅឡើយទេ ព្រោះរុក្ខជាតិប្រភេទនេះក្រោយពេលឃើញផ្កា ហើយកំរនឹងបានឃើញផ្លែវាណាស់ (សួន ធីរស់, ២០០៥)។

**ច-ការបន្តពូជ**

ការបន្តពូជរបស់ដើមម្រះព្រៅភ្នំនេះគឺ អាចបន្តពូជបានតាមរយៈឫសរបស់វា អាចចាក់ទៅដល់ណាពេលដែលឫសរបស់វាហើបឡើងមកលើដី ក៏ចាប់ផ្ដើមដុះពន្លកហើយ ចាប់ផ្ដើមដុះឫសចាក់ទៅក្រោម បង្កើតបានទៅជាដើមមួយ ថ្មីបន្តទៀត ឬ ពេលណាដែលខ្យល់បក់ខ្លាំងធ្វើឱ្យមែករបស់វាបាក់ដាច់ធ្លាក់មកក្រោមពេលនោះ មែកនេះធ្លាក់ដោតជាប់នឹងដី ឬ ប៉ះដី មួយរយៈក្រោយមកវាក៏ចាប់ផ្ដើមដុះឫស ឬ ពន្លកច្រើននៅលើមែកនោះ បន្ទាប់មកក៏ចាប់ផ្ដើមចាក់ឫសចុះក្រោមចំពោះពន្លកណាដែលធន់ទ្រាំនឹងសីតុណ្ហភាពបានរយៈពេលយូរភាពរាំងស្ងួត កំដៅថ្ងៃខ្យល់ខ្លាំងដែលជះឥទ្ធិពលមកលើពន្លកនោះ ព្រោះពេលដែលត្រូវដុះគឺត្រូវការសំណើមម្លប់ត្រជាក់យូរ ។ល។ ឯការបន្តពូជដោយគ្រាប់ពុំទាន់មានការសង្កេតឃើញនៅឡើយទេ (សួន ធីរស់, ២០០៥)។

**ចំណើរការចំរាញ់ប្រេងម្រះព្រៅភ្នំ និងផលប៉ះពាល់លើបរិស្ថាន**

ដើមម្រះព្រៅភ្នំជាប្រភេទរុក្ខជាតិដែលពុំមានលក្ខណៈសមប្រកបជាមួយគ្រឿងសំណង់ធំៗ វែងៗ នោះទេ ដោយសារតែដើមរបស់វាផ្ទុកទៅដោយសារធាតុប្រេង និង ប្រហោងក្នុង

ផ្នែកបណ្ដូលនៅពេលដែលដើមរបស់វាកាន់តែធំ ។ លើសពីនេះទៅទៀតនោះប្រេងដែលផ្ទុកនៅក្នុងដើមអាចចំរាញ់យកប្រេងមកប្រើប្រាស់ក្នុងមធ្យោបាយជាច្រើនទៀតផង។ តាមការសិក្សានៃមន្ទីពិសោធន៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនបានឱ្យដឹងថា ប្រេងម្រះព្រៅភ្នំ មានផ្ទុកទៅដោយសារធាតុសាហ្វ្រូលខ្ពស់រហូតដល់ ៩៦ភាគរយ ។

## ១. ដំណាក់កាលរៀបចំមុនធ្វើការចំរាញ់

### ក-ការរៀបចំឆ្នាំងចំហុយ

ឆ្នាំងចំហុយត្រូវបានយកបន្ទះដែកមកផ្សារភ្ជាប់គ្នាឱ្យចេញជារាងមូល ហើយមានបាតឆ្នាំងស្មើល្អ មានអង្កត់ផ្ចិតប្រវែង ២ម៉ែត្រ កម្ពស់ ១.៨ម ។ នៅនឹងមាត់ឆ្នាំងគេបានផ្សារភ្ជាប់ធ្វើជាធុងទឹករាងមូលព័ទ្ធជុំវិញ អាចមានជម្រៅ ១៥ស.ម ទទឹង ១៥ស.ម ដែលប្រើសម្រាប់ដាក់ទឹកនៅពេលគេយកគំរបឆ្នាំងមកគ្រប ។ គេធ្វើបែបនេះដើម្បីការពារផ្សែង ឬការបាត់បង់នូវចំហាយទឹក និង ប្រេងនៅពេលភាយចេញតាមគំរប ។ នៅជាប់នឹងសាច់ដែកនៃឆ្នាំងនៅត្រង់កន្លែងដែលភ្ជាប់ធុងទឹក គេចោះរន្ធនៅកំពស់ប្រមាណជា ១០ ស.មពីបាតធុង។

### ខ-គំរបឆ្នាំង

ឆ្នាំងចំរាញ់ប្រេងម្រះព្រៅភ្នំនេះ គេរៀបបង្កើតឱ្យមាន



ឆ្នាំងចំរាញ់ប្រេងម្រះព្រៅភ្នំ

គំរបឆ្នាំងដូចជាគំរបឆ្នាំងបិទស្រាដែរ ។ ប៉ុន្តែគំរបរបស់វាមាន ទម្ងន់ និង ទំហំធំជាង ។ គំរបឆ្នាំងត្រូវបានគេធ្វើឡើង ដោយមានរាងដូចជាសាជី និង ផ្នែកកំពូលលើគេចោះឱ្យមានរន្ធសម្រាប់ភ្ជាប់ជាមួយទុយោ ដើម្បីបង្ហូរចំហាយល្បាយ ទឹក ប្រេង និង ជ័រចូលទៅក្នុងឆ្នាំងស្អំដែលត្រូវបានគេត្រាំនៅក្នុងទឹក ។



*គម្របឆ្នាំងចំរាញ់ប្រេងម្រះព្រៅភ្នំមើលពីចំហៀង នៅស្រុកសំឡូត*

### គ-បំពង់សម្រាប់ស្រោចពីលើគំរប

បំពង់សម្រាប់ស្រោបពីលើបំពង់គម្របឆ្នាំងពីខាងក្រៅមានមួយដូចរូបថតគំរបឆ្នាំងខាងលើ ។ ជាទូទៅប្រវែងរបស់បំពង់នេះមានភាពប្រែប្រួលទៅតាមចំងាយ ឬ ទីតាំងឆ្នាំងស្អំដែលត្រូវបានគេដាក់ត្រាំនៅក្នុងទឹក ដែលអាចមានប្រវែងពី ៦ ទៅ ៨ ម៉ែត្រ។ ក្រៅពីនេះនៅមានបំពង់សម្រាប់ស្រោបទុយោនេះមួយទៀតសម្រាប់ភ្ជាប់ជាមួយនឹងឆ្នាំងស្អំ ។

### ឃ-ធុងស្អំប្រេងម្រះព្រៅភ្នំ

ធុងស្អំត្រូវបានគេប្រើប្រាស់ដើម្បីបញ្ចុះកំដៅចំហាយប្រេង ជ័រ និង ទឹកដែលភាយចេញព្រមគ្នា ក្នុងពេលដំណើរការចំរាញ់ ។ *ធុងស្អំមានទំហំ ១,៨០ ម x ២ម x ១ម ដែលមានគំរប* បិទជិតដែលទុកតែច្រកមួយ ដើម្បីឱ្យចំហាយប្រេង ទឹក និង ជ័រចូល។ នៅនឹងបាតធុងស្អំ គេបង្កើតឱ្យមានរន្ធតូចមួយ ដើម្បីធ្វើការបង្ហូរយកប្រេង និង ជ័រ (ញែករវាងប្រេង និង ជ័រ) ។



ឆ្នាំងស្អំ ដើម្បីបញ្ចុះកំដៅចំហាយប្រេង-ទឹក-ជ័រ
(បង្កប់ត្រាំនៅខាងក្រោម)

### ង-ធុងសម្រាប់ត្រងប្រេងម្រះព្រៅភ្នំ

ធុងសម្រាប់ត្រងប្រេងម្រះព្រៅភ្នំនេះ មានរាងមូលបាតរាបស្មើធម្មតាមានទំហំធំល្មម នៅក្នុងនេះមានសន្ទះដែកពីរបន្ទះ សម្រាប់ទប់ទឹកប្រេង និង ជ័រ ។ នៅខាងលើមាត់ធុងនេះ មានចោះរន្ធសម្រាប់បង្ហូរទឹកចេញចោល ក្នុងករណីនេះប្រេងមានទម្ងន់ធ្ងន់ជាងទឹក ត្រូវធ្លាក់ចុះទៅដល់បាតក្រោមនៃធុង ដូចនេះកាលណាប្រេងធ្លាក់ចូលកាន់តែច្រើន ទឹកកាន់តែអណ្តែតឡើងលើ ដែលអាចហូរចេញតាមរន្ធដែលគេចោះនៅកៀកនឹងមាត់ធុងខាងលើ បើកាលណាប្រេងពេញធុងនេះ ហើយគេត្រូវយកធុងនេះចាក់ប្រេងជ័រចេញ និង អាចនៅសល់ទឹកខ្លះទៀត ប៉ុន្តែភាគច្រើនក្នុងការចំហុយយកប្រេងក្នុងមួយឆ្នាំងៗ ច្រើនតែពេញធុងនេះល្មម ដោយពុំពិបាកដកហូតយកមកចាក់ពេលកំពុងចំហុយឡើយ ។

### ច-តុសម្រាប់ដាក់ដែកឈូស

តុដាក់ដែកឈូសត្រូវបានគេសាងសង់ឡើង ដើម្បីធ្វើការចិតចិញ្ច្រាំដុំម្រះព្រៅភ្នំ ដែលគេបំបែករួចឱ្យទៅជាចំណិតស្តើងៗ ដើម្បីងាយក្នុងការចំរាញ់យកប្រេងពីក្នុងសាច់ឈើម្រះព្រៅភ្នំ ។ ជាទូទៅតុដាក់ដែកឈូសនេះ ត្រូវបានធ្វើតំរូវទៅតាមប្រវែងផ្លែដែកឈូសដែលគេបានទិញ ហើយគេធ្វើឱ្យមានរាងជំរាលបន្តិច ដើម្បីជាការងាយក្នុងការឈូស ។ កំណាត់ឈើ ឬ ដុំម្រះព្រៅភ្នំដែលបានពុះជាកំណាត់តូចៗទម្ងន់ប្រហែល ១០ គីឡូក្រាម ត្រូវបានគេធ្វើការឈូសជាចំណិតស្តើងៗទៀត បន្ទាប់មកទើបគេយកចំណិតស្តើងនៃសាច់ឈើម្រះព្រៅភ្នំដាក់លើកញ្ច្រែង និងដាក់ចូលទៅក្នុងឆ្នាំងចំហុយ ។ ក្នុងការឈូសនេះ កម្មករគ្រាន់តែប្រើប្រាស់កម្លាំងដើម្បីទប់កំណាត់ឈើតែប៉ុណ្ណោះ ព្រោះថាកម្លាំងវិលនៃដែកឈូសដែលដាក់លើតុ ធ្វើចលនាដោយកម្លាំងម៉ាស៊ីនទាញ ។ ដែកឈូសនេះមានរាងមូល ដែលអាចដាក់នៅលើតុដែលធ្វើអំពីដែក ឬ អំពីឈើក៏បាន ប៉ុន្តែជើងតុដាច់ខាតត្រូវកប់ចូលទៅក្នុងដីឱ្យបានរឹងមាំ ព្រោះការឈូសត្រូវការកម្លាំងទប់ទល់ទម្ងន់ឈើ និងកម្លាំងសង្កត់ ។ ម្យ៉ាងទៀតត្រូវទប់ជាមួយកម្លាំងទាញរបស់ខ្សែពានម៉ាស៊ីន ដើម្បីប្រើកម្លាំងឈូស ។



តុដែកឈូស និង ចំណាំងសាច់ឈើម្រះព្រៅភ្នំនៅស្រុកសំឡូត

ចំពោះតុឈូសនេះ ជាទូទៅគេពុំបានដាក់ឆ្ងាយពេកពីរានឡើងដាក់ចំណាំងឈើនេះចូលទៅក្នុងឆ្នាំងនោះទេ ពិសេសគឺនៅក្បែរឆ្នាំង ដើម្បីចំណេញពេលវេលា និង កម្លាំងក្នុងការជញ្ជូន ។ នៅជិតតុឈូសមានម៉ាស៊ីនមួយសម្រាប់អូសដែកឈូស ។ ម៉ាស៊ីននេះប្រើសម្រាប់តែដែកឈូសនេះមួយគត់ក្នុងការឈូសយកចំណាំងឈើនោះ ។



*កញ្ច្រែងសម្រាប់ដាក់ចំណាំងសាច់ឈើ*

### ឆ-កញ្ច្រែងសម្រាប់ផ្ទុកចំណាំងឈើ

កញ្ច្រែងនេះមានរាងមូលមានទំហំល្មម និង អាចដាក់ចូលទៅក្នុងឆ្នាំងចំហុយបាន ។ កញ្ច្រែងនេះមានលួសចាក់ស្រេះស្ទើរតែជិត ដែលមានរាងជាក្រឡាសំណាញ់ និង មានភាពរឹងមាំខ្លាំងណាស់ ។ នៅក្នុងឆ្នាំងនីមួយៗត្រូវបានគេប្រើកញ្ច្រែងនេះចំនួនពីរ ឬ បី ។

### ជ-ការរៀបចំឆ្នាំង

ក្រោយពីគេបានធ្វើការរៀបចំបំពង់ធុងស្ងំ ធុងត្រងប្រេងទៅដល់ទីតាំងមួយដល់ទីតាំងមួយដ៏សមស្របដែលមានទីវាលស្រឡះល្អ ហើយមានអូរទឹកមិនចេះរីងស្ងួតទាំងប្រាំងទាំងវស្សា នោះគេចាប់ផ្តើមរៀបចំចង្ក្រាន ដែលផ្សំឡើងពីថ្មដុំៗ មកដាក់ជិតៗគ្នា ហើយក៏ប្រមូលយកដីដែលមានជាតិស្អិត (ដីឥដ្ឋ) មកជាន់លាយទឹករហូតដល់ស្អិតល្អហើយទើបធ្វើការជីករណ្តៅសម្រាប់ធ្វើចង្ក្រាន ដែលមានជំរៅប្រែប្រួលទៅតាមទំហំឆ្នាំង ។ នៅខាង ក្រោមចង្ក្រានមានបង្កើតជាប្រហោងមួយសម្រាប់ដុតអុសនិងជាកន្លែងដែលត្រូវបានគេប្រើប្រាស់ដែកដើម្បីទ្រទ្រង់ទម្ងន់របស់ឆ្នាំង ។ ដែក

ដែលប្រើប្រាស់ដើម្បីទ្រទ្រង់ទម្ងន់របស់ឆ្នាំងមានចំនួន ៥កំណាត់ រហូតដល់អាចកប់ឆ្នាំងបានពាក់កណ្តាលឆ្នាំងដែលបានបិទដីជិត ជាមួយនឹងដុំថ្ម ព្រោះបើពុំនោះទេ វាធ្វើឱ្យអណ្តាតភ្លើងអាចវិលជុំវិញឆ្នាំងបានតាមសំរួល និង សព្វ ។




*មាត់ចង្ក្រានចំរាញ់ប្រេងម្រះព្រៅភ្នំ*

## ២. ដំណើរការចំរាញ់ប្រេងម្រះព្រៅភ្នំ

បន្ទាប់ពីបានធ្វើការរៀបចំចង្ក្រានរួចហើយ គេក៏លើកយកឆ្នាំងមកដាក់ពីលើចង្ក្រានរួច ហើយគេចាប់ផ្តើមដំណើរការឈូសកំណាត់ដើមម្រះព្រៅភ្នំឱ្យទៅជាចំណិតស្តើងៗដូចស្លឹកស្រូវ និង ដឹកជញ្ជូនទៅកាន់ឆ្នាំង ដោយដាក់រហូតដល់ពេញចំណុះឆ្នាំង ២ តោន ឬ ១,៥ តោន អាស្រ័យទៅតាមទំហំឆ្នាំងដែលអ្នកផលិតប្រើ ។ ជាទូទៅគេប្រើប្រាស់ឆ្នាំងដែលមានទំហំ ២ តោន ដើម្បីចំរាញ់ប្រេងម្រះព្រៅភ្នំ ព្រោះវាមិនត្រឹមតែចំណេញពេលវេលាចំរាញ់នោះទេ ថែមទាំងចំណេញនូវឈើថាមពលទៀតផង ។ ទោះបីជាយ៉ាងណាក៏ដោយក៏មួយលើកនៃការចំរាញ់គេប្រើប្រាស់ឈើថាមពល ជាមធ្យម ២ ទៅ ៣ ម៉ែត្រគូប ។ កំទេចចំណាំងឈើម្រះព្រៅភ្នំ ត្រូវបានគេយកដាក់លើកញ្ច្រែងដែលក្នុងមួយឆ្នាំង ត្រូវបានគេប្រើកញ្ច្រែងពីរទៅបីកញ្ច្រែង អាស្រ័យទៅតាមជំរៅឆ្នាំងដែលបានប្រើ ។ ការផ្ទុកចំណាំងសាច់ឈើម្រះព្រៅភ្នំនៅលើកញ្ច្រែងនេះ មានគោលបំណងដើម្បីងាយស្រួលក្នុងការរើយកកំទេច ឬ កាកសំណល់ឈើដែលបានដកហូតយកប្រេងរួចចេញពីក្នុងឆ្នាំង និង ដាក់នូវចំណាំងថ្មីចូល ។

ការលើកដាក់កញ្ច្រែងដែកត្រូវបានគេប្រើប្រាស់កៅឡាក់ស្ទូច ដើម្បីជួយសំរួលដល់កម្លាំងកម្មករ និង ពេលវេលា ។ លើសពីនេះទៀតកៅឡាក់ក៏ត្រូវបានប្រើ ដើម្បីជួយលើកគំរបឆ្នាំងផងដែរ ។ បន្ទាប់ពីដាក់ចំណាំងសាច់ឈើម្រះព្រៅភ្នំទៅក្នុងឆ្នាំងពេញរួចទឹកត្រូវបានគេចាក់បំពេញ ដោយលៃយ៉ាងណាឱ្យនៅសល់ ៣០សម ពីមាត់ឆ្នាំង ។ ការរក្សាទុកនេះគឺដោយសារការពារ នៅពេលដែលកំដៅឡើងក្តៅរហូតទឹកពុះនោះ ធ្វើឱ្យផុលគំរប និង បាត់បង់នូវចំហាយទឹក ប្រេង និង ជ័រម្រះព្រៅភ្នំ ។ ការចំរាញ់នេះប្រើប្រាស់រយៈពេលរហូតដល់ទៅ ៦-៧ ម៉ោង ។ ក្នុងមួយឆ្នាំងជាទូទៅគេចំរាញ់បានប្រេងជាមធ្យម ៣០ លីត្រ ។ ចំហាយទឹក ប្រេង និង ជ័រ ដែលភាយចេញពីឆ្នាំងចំរាញ់ ត្រូវបានបញ្ចូលទៅក្នុងឆ្នាំងស្អំ ក្នុងគោលបំណងបញ្ចុះកំដៅ និង បង្ហូរចេញនូវប្រេង ជ័រ និង ទឹក ដើម្បីធ្វើការញែកយកប្រេង ។




*គំនូសបំព្រួញបង្ហាញទីរចនាសម្ព័ន្ធឡចំរាញ់ប្រេងម្រះព្រៅភ្នំ*

## ៣.ផលប៉ះពាល់ការចំរាញ់ប្រេងម្រះព្រៅភ្នំលើបរិស្ថាន

ការចំរាញ់ប្រេងម្រះព្រៅភ្នំបានបង្កឱ្យមានផលប៉ះពាល់ជាច្រើនដល់បរិស្ថាន និង ធនធានធម្មជាតិដែលស្ថិតនៅជុំវិញ ដូចជា :

### ក -ការតំរាចក់ហែងធនធានព្រៃឈើ

ប្រភេទដើមឈើជាច្រើនប្រភេទដែលស្ថិតនៅទីតាំងជុំវិញឡចំរាញ់ត្រូវបានកាប់មកធ្វើជាអុសដុតសម្រាប់ផ្គត់ផ្គង់ដំណើរការចំរាញ់ប្រេងម្រះព្រៅភ្នំ ។



*ឈើដែលគេកាប់សម្រាប់ដុតចំរាញ់ប្រេងម្រះព្រៅភ្នំ*

ម្យ៉ាងទៀតប្រភេទឈើប្រណិតដែលមានតម្លៃនៅក្នុងតំបន់នោះក៏រងនូវការគំរាមកំហែងផងដែរ ។

**ខ-ការគំរាមកំហែងដល់ប្រភពទឹក**

កាកសំណល់ដែលសល់ពីការចំរាញ់ប្រេងម្រះព្រៅភ្នំ ត្រូវបានគេចាក់ចោលនៅទីតាំងប្រភពទឹកតែម្តង ដែលជាហេតុបង្កឱ្យមានការបំពុលនូវប្រព័ន្ធផ្លូវទឹកផងដែរ ។



*កាកសំណល់ដែលសល់ពីការចំរាញ់យកប្រេង*

**គ-ការបំផ្លាញនូវជីវចំរុះនៅក្នុងតំបន់**

តំបន់ដែលមានដើមម្រះព្រៅភ្នំដុះ និង មានការចំរាញ់យកប្រេងរបស់វានោះ គេសង្កេតឃើញថាព្រៃឈើនៅក្នុងតំបន់នោះភាគច្រើនត្រូវបានបាត់បង់នូវគំរបដី និង រុក្ខជាតិតូចធំ ក៏ត្រូវបានខូចខាតដោយសារតែការរងនូវការដួលសង្កត់ពីលើនៃដើមម្រះព្រៅភ្នំដែលបានកាប់រំលំនោះ ។

ចំពោះការរស់នៅរបស់សត្វ គឺត្រូវបានរងនូវការគំរាមកំហែងដោយបាត់បង់ទីជំរក និងប្រភពចំណីរបស់វាទាំងស្រុង ។ លើសនេះទៀតនោះ ប្រភេទសត្វទាំងនោះក៏រងទទួលនូវការគំរាមកំហែងលើជីវិតរបស់វាផងដែរដោយសារតែកម្មករដែលទៅចំរាញ់ប្រេងម្រះព្រៅភ្នំនៅក្នុងព្រៃនោះ អាចនាំគ្នាដាក់អន្ទាក់ចាប់សត្វធ្វើជាចំណីអាហារទៀតផង ។

**៤.សន្និដ្ឋាន**

ដំណើរការចំរាញ់ប្រេងម្រះព្រៅភ្នំនេះធ្វើឡើងដោយលួចលាក់ និង ពុំមានការអនុញ្ញាតឡើយ ដែលត្រូវបានចាត់ទុកថាជាបទល្មើសព្រៃឈើមួយក្នុងចំណាត់ថ្នាក់បទល្មើសព្រៃឈើថ្នាក់ទី១ ( មាត្រា ៩៧.- ចំនុច ៩- បង្កើតមូលដ្ឋានកែច្នៃ វល្លិ រមៀត ឬ មូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀត ដែលនាំមកនូវការបំផ្លាញព្រៃឈើ និង មជ្ឈដ្ឋានព្រៃឈើ )។ ដោយឃើញនូវសកម្មភាពបំផ្លិចបំផ្លាញដល់សម្បត្តិធម្មជាតិ និង មានការគំរាមកំហែងដល់សង្គមរុក្ខជាតិ ដែលស្ថិតនៅជុំវិញតំបន់ នោះ ទើបរាជរដ្ឋាភិបាលកម្ពុជាបានខិតខំចាត់វិធានការបង្ក្រាបរួមទាំងការអប់រំប្រជាជនឱ្យឈប់ប្រព្រឹត្តបទល្មើសនេះទៀតផង ។ ទោះបីជាមានការបង្ក្រាបយ៉ាងតឹងរឹងយ៉ាងណាក៏ដោយក៏សកម្មភាព នៃការចំរាញ់ប្រេងម្រះព្រៅភ្នំដោយជនល្មើសនៅតែលួចលាក់បន្តការងាររបស់ខ្លួនជាសំងាត់។

